ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៦៧៥ / ១១-១១-០៩

<u>សាលដីកា</u>

លេខ ១៥ "ក្រ III ច" / ២៩-០៣-២០១១

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើ តាមក្រិត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ១០-០៣-២០១១ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជំរះ**

លោកស្រី [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៦៧៥ / ១១-១១-២០០៩ រវាង :

**១-ជនជាប់ចោទ**ឈ្មោ[redacted]ភទប្រុស អាយុ ៣៧ ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិតាម៉ៅកណ្តាល ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ឪពុកឈ្មោ[redacted] ម្តាយឈ្មោះ[redacted] ប្រពន្ធឈ្មោះ[redacted]ានកូន ០៧ នាក់ ទោសពីមុនគ្មាន ឃុំខ្លួន ១៧-០៩-២០០៧ (នៅពន្ធនាគារខេត្តក្រចេះ) ។

-មានមេធាវីការពារលោ[redacted]

**ត្រូវជាប់ចោទពីបទ** : ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី ១៥-០៩-២០០៧ បទល្មើសឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។



Scanned by CamScanner

២-ដើមបណ្ដឹងរដ្ឋប្បវេណី [redacted] ភេទស្រី អាយុ ១៨ ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិតាម៉ៅ កណ្ដាល ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ 37/4

## ងរឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ២៤-០៤-២០០៧ [redacted] និ [redacted] ដែលត្រូវជាឪពុកចុង បានទៅធ្វើកម្មករដាំកូនឈើឱ្យក្រុមហ៊ុនចិននៅឃុំអូរគ្រៀង ក៏បានដេករួមរក្សទឹងគ្នាជាញឹកញាប់ច្រើនលើកមក ហើយ លុះដល់ថ្ងៃទី ១៥-០៩-២០០៧ ជនជាប់ចោទឈ្មោ [redacted] បានមកហៅជនរងគ្រោះឈ្មោះ [redacted] ឱ្យទៅដេកជាមួយ តែជនរងគ្រោះមិនព្រមទៅ ក៏ប្ដឹងសមត្ថកិច្ចឱ្យចាប់ខ្លួនតែម្ដង ។

-**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ ៦២ "ក" ចុះថ្ងៃទី ១១-០៩-២០០៩ របស់សាលាដំបូងខេត្ត ក្រចេះ ដែលបានសំរេចសេចក្ដីដូចខាងក្រោម :

**១-សំរេច**ឱ្យឈ្មោ [redacted] ភេទប្រុស អាយុ ៣៧ ឆ្នាំ ជាតិខ្មែរ រួចខ្លួនពីបទ ប៉ុនប៉ងរំលោភ សេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី ១៥-០៩-២០០៧ បទល្មើសឱ្យផ្ដន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងបង្គាប់ឱ្យដោះលែងឈ្មោះនេះ ចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ភ្លាម ប្រសិនបើឈ្មោះនេះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀតទេ ។

២-សាលក្រមនេះបានជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោ [redacted] និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោ [redacted] បើកផ្លូវប្ដឹងផ្លូវឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

## នាពេលសវនាការ

-**ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង**

-ជនជាប់ចោទ [redacted] អវត្តមាន )

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោ [redacted] ( អវត្តមាន )

-ក្រឡាបញ្ជី បានអានចម្លើយរបស់ជនជាប់ចោទ ដើមបណ្ដឹង និងសាក្សី ។

## តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន

បើពិនិត្យទៅលើចម្លើយជនជាប់ចោទ សាក្សី និងជនរងគ្រោះ មានការប្រែប្រួលចម្លើយ ទៅ ព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋាន សុំឱ្យក្រុមប្រឹក្សាពិចារណាតាមមាត្រា ២៧ កថាខណ្ឌទី ៤ នៃក្រមព្រហ្មទណ្ឌ ។ តែលោកព្រះរាជអាជ្ញ [redacted] ដែលឡើងមកធ្វើសេចក្ដីសន្និដ្ឋានទៅពេលសវនាការ យល់ឃើញថា ឪពុកពិតជាបានប្រព្រឹត្តបទល្មើសចាប់រំលោភទៅលើកូនមែន សុំឱ្យក្រុមប្រឹក្សាជំនុំជំរះផ្ដន្ទាទោស ទៅតាមច្បាប់ ។





Scanned by CamScanner

## មេធាវីធ្វើសេចក្តីសន្និដ្ឋាន

តាមចម្លើយរបស់ជនរងគ្រោះនៅពេលសវនាការ បានឆ្លើយថា ឪពុកខ្លួនមិនបានរំលោភលើខ្លួនទេ ចម្លើយជនជាប់ចោទក៏បានឆ្លើយដែលនៅពេលសវនាការថា ខ្លួនក៏មិនបានរំលោភលើកូនទេ នៅពេលដែលខ្លួនហៅកូនឱ្យមកដេកជាមួយនោះ ដោយសារកន្លែងក្រុមហ៊ុនមានការផ្លាស់ប្តូរទីតាំងដាំដើមឈើ ហើយមានភាពច្របូកច្របល ខ្លួនក៏ទៅហៅកូនឱ្យមកដេកជាមួយ នៅពេលនោះបងស្រីខ្លួនខឹងខ្លាំងពេកក៏ហៅប៉ូលីសឱ្យចាប់ខ្លួនម្តងទៅ ។ សំណូមពរសុំក្រុមប្រឹក្សាជំនុំជំរះ តម្កល់សាលក្រមរបស់សាលាដំបូងខេត្តក្រចេះ ទុកជាបានការ ។

## តុលាការថយទៅពិភាក្សា

ក្រោយពីបានពិនិត្យ ឯកសារក្នុងសំណុំរឿងហើយ ។

ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី ។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ ។

## សាលាឧទ្ធរណ៍

## យល់ឃើញថា :

១-បណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី ១៤-០៩-២០០៩ របស់លោ[redacted]ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តក្រចេះ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦២ "ក" ចុះថ្ងៃទី ១១-០៩-២០០៩ របស់សាលាដំបូងខេត្តក្រចេះ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមចម្លើយសារភាពរបស់ជនជាប់ចោទនៅដំណាក់ ការស៊ើបសួរបានឆ្លើយស៊ីសង្វាក់ និងចម្លើយជនរងគ្រោះ សាក្សី និងរបាយការណ៍កើតហេតុចុះថ្ងៃទី ១៦-០៩-២០[redacted]ពេញសន្តិសុខក្រុមហ៊ុន G T N ជាំ Globl អំពីសកម្មភាព និងទង្វើរបស់ជនជាប់ចោទទៅលើជនរងគ្រោះដែលជាកូនរបស់ប្រពន្ធ ។ ឃើញថាជនជាប់ចោទពិតជាបានរំលោភបំពានផ្លូវភេទជាមួយកូនចុងខ្លួនឯងជាច្រើនលើកច្រើនសារដោយសារការគំរាមកំហែង តែនៅថ្ងៃទី ១៥-០៩-២០០៧ នេះជនជាប់ចោទនៅតែបន្តគំរាមជនរងគ្រោះឱ្យទៅដេកជាមួយខ្លួនទៀតក្នុងគោលបំណងរំលោភបំពានផ្លូវភេទទោះបីសន្តិសុខធ្វើការហាមឃាត់ក៏ជនជាប់ចោទនៅតែផ្ទោះរបងចូលអូសដៃជនរងគ្រោះ ទាល់តែសន្តិសុខចាប់ឃាត់ខ្លួនធ្វើកំណត់ហេតុរួចបញ្ជូនមកតុលាការ ចាត់ការតាមផ្លូវច្បាប់ ។

៣-សកម្មភាព និងអំពើរបស់ជនរងគ្រោះគឺជាការប៉ុនប៉ងរំលោភលើកូនស្រីចុងខ្លួនឯង ដែលធ្លាប់តែគំរាមរំលោភបានសំរេចជាច្រើនលើក កន្លងមក ។

៤-ទោះបីជនរងគ្រោះ បានដកបណ្តឹងបានឈប់ប្តឹងពីជនជាប់ចោទថា មិនបានរំលោភខ្លួន ហើយជនជាប់ចោទបានបដិសេធថា ការឆ្លើយពីមុនថា បានរំលោភ និងប៉ុនប៉ងរំលោភ មិនជាការពិតទេ គឺឆ្លើយដើម្បីឱ្យស្រប



Scanned by CamScanner

និងចម្លើយជនរងគ្រោះនោះ គឺជាការលាក់បាំង នូវអំពើល្មើសច្បាប់របស់ខ្លួន ។ ព្រោះថា គ្មានជនណាម្នាក់ដែលគេចោទប្រកាន់ហើយ ខ្លួនមិនបានប្រព្រឹត្តបែរជាសារភាពទទួលស្គាល់ នូវអំពើនោះគ្មានទេ។ ចម្លើយទាំងនេះ គឺជាចម្លើយនៅសវនាការ សាលាដំបូង គឺជាចម្លើយមិនអាចយកជាការបានឡើយ ។ ការដកបណ្តឹងរបស់ជនរងគ្រោះមិនអាចអនុគ្រោះដល់អំពើល្មើសរបស់ជនជាប់ចោទបានឡើយ ។

៥_ការឱ្យជនជាប់ចោទរួចផុតពីបទចោទរបស់សាលាដំបូងខេត្តក្រចេះ គឺគ្មានសំអាងអ្វីក្រៅពីការដែលជនជាប់ចោទបដិសេធចម្លើយនៅដំណាក់ការស៊ើបសួរ ហើយទទួលយកចម្លើយនៅពេលសវនាការ និង ការដកបណ្តឹងរបស់ជនរងគ្រោះមកធ្វើជាសំអាងឱ្យជនជាប់ចោទរួចផុតពីបទចោទ គឺមិនត្រឹមត្រូវតាមលក្ខណៈច្បាប់ឡើយ ។

៦_អំពើ និងសកម្មភាពរបស់ជនជាប់ចោទ ដែលប្រព្រឹត្តបែបនេះ វាខុសនឹងច្បាប់ដែលហាមឃាត់ វាជាទង្វើអសីលធម៌ និងប្រពៃណីរបស់ខ្មែរ (ដែលជាឪពុករំលោភកូន ) ដែលធ្វើឱ្យជនរងគ្រោះទទួលការឈឺចាប់ទាំងផ្លូវរូបកាយ ផ្លូវចិត្ត ។

៧_មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទ ពីបទ : ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី ១៥-០៩-២០០៧ បទល្មើសឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៨_សាលក្រមព្រហ្មទណ្ឌលេខ ៦២ "ក" ចុះថ្ងៃទី ១១-០៩-២០០៩ របស់សាលាដំបូងខេត្តក្រចេះ បានសំរេចសេចក្តី ពុំត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ឡើយ គប្បីបដិសេធសាលក្រមចោលជាអសារបង់ ហើយសំរេចឡើងវិញ តាមការយល់ឃើញខាងលើ ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

១_ទទួលបណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី ១៤-០៩-២០០៩ រ[redacted]ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តក្រចេះ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២_បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ៦២ "ក" ចុះថ្ងៃទី ១១-០៩-២០០៩ របស់សាលាដំបូងខេត្តក្រចេះ ចោលជាអសារបង់ ។

**៣_ផ្តន្ទាទោសលើឈ្មោះ** [redacted] ភេទប្រុស អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិតាម៉ៅ កណ្តាល ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ឪពុកឈ្[redacted] ម្តាយឈ្មោ[redacted] ប្រពន្ធឈ្មោ[redacted]ូន ០៧ នាក់ ទោសពីមុនគ្មាន ដាក់ពន្ធនាគារកំណត់ **១០ ឆ្នាំ ( ដប់ឆ្នាំ )** គិតពីថ្ងៃឃុំខ្លួន ១៧-០៩-២០០៧ **ពីបទ** : ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី



Scanned by CamScanner

37

៤-បន្តឃុំខ្លួនជនជាប់ចោទឈ្មោ[redacted]ច្បាប់ ។

៥-សាលដីកានេះជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី ១០-០៣-២០១១ ប្រកាសជាសាធារណៈនៅថ្ងៃទី ២៩-០៣-២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងជនរងគ្រោះ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| --- | --- | --- |
| ហត្ថលេខា[redacted] | ហត្ថលេខា[redacted]. [redacted] | ហត្ថលេខា[redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី ២៩ ខែ 3 ឆ្នាំ ២០១១

| បានឃើញ | |
| --- | --- |
| ប្រធានក្រុមប្រឹក្សាជំនុំជំរះ | ក្រឡាបញ្ជី |
| [redacted] | [redacted] |





Scanned by CamScanner